# ល្បែង៖ ប្រណាំងខ្វារសម្ភារ ឬកូនបាល់

**កម្មវិធីសិក្សា៖**

**ចិត្តចលភាព៖** បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង

ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**រយៈពេល៖** ៣០ នាទី

**ឧបករណ៍៖** ក្រដាសកេះ កាំភ្លើងបាញ់កាវ ចង្កឹះ ឬឈើឬស្សីដែលមានប្រវែងវែងល្មម កន្ត្រៃ ដបទឹក គម្របដបដែលមានច្រើនពណ៌ ហ្វឹត ឬដីខ្មៅពណ៌

**គោលបំណង៖** (ចិត្តចលភាព) ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។ (សិក្សាសង្គម)៖ ប្រាប់បានពីការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… និងបង្កើតរូបភាពផ្សេងៗ។

**ត្រៀម៖** ធ្វើសម្ភារ១ឬ២ឈុតសម្រាប់បង្ហាញកុមារមុនពេលដែលត្រូវលេងល្បែងសកម្មភាពមួយនេះ។

**សេចក្តីណែនាំ៖**

១. ប្រាប់ក្មេងៗថាថ្ងៃនេះយើងនឹងលេងល្បែងសកម្មភាពមួយដែលមានចំណងជើងថា៖ ល្បែង

២. បង្ហាញកុមារពីរសម្ភារដែលប្រើសម្រាប់លេងល្បែងសកម្មភាពនេះជាមុនសិន

៣. ប្រសិនបើមានពេលនោះ អ្នកគួរតែបង្រៀនកុមារឱ្យចេះផលិតសម្ភារសម្រាប់លេងល្បែងនេះក៏បាន។

៤. ចែកកុមារជាក្រុមៗដែលមានចំនួន២នាក់។

៥. ពួកគាត់ត្រូវប្រណាំងគ្នាខ្វារយកគម្របដបឱ្យបានច្រើនជាងគេផងដែរ

៦. អ្នកត្រូវកំណត់នាទី ក្នុងការលេងល្បែងសកម្មភាពមួយនេះ ឬអស់ចំនួនគម្របដបដែលបានដាក់នៅក្នុងក្រដាសកេះនោះ។

៧. ឱ្យកុមារលេងម្តងមួយក្រុមៗ ទល់តែអស់កុមារនៅក្នុងថ្នាក់តែម្តង។

៨. ពេលលេងរួចរាល់សូមប្រាប់ឱ្យកុមារជួបរៀបចំសម្ភារទុកឱ្យបានត្រឹមត្រូវជាការស្រេច។

**បញ្ជាក់៖** ល្បែងនេះអាចលេងជាប្រភេទផ្សេងដោយប្រើគ្រាប់ជាគ្រាប់ឃ្លី កូនបាល់តូចដែលធ្វើពីក្រដាសជូតមាត់ក៏បានដែរ សូមជ្រើសរើសយកអ្វីដែលងាយ និងមិនចំណាយថវិការ ឬចំណាយតិចបំផុត។